ភ្នំពេញ ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៣

# ប្រកាសលេខ ០០៧ កសហ.ប្រក
## ស្តីពីការសងប្រាក់ពន្ធ ចំពោះផលិតផលនាំចូល
## ដែលជាប់អាករពន្ធខ្ពស់ហើយត្រូវនាំចេញទៅវិញ

* * * *

- បានឃើញ ព្រះរាជក្រឹត្យរបស់សម្តេចព្រះឧបយុវរាជ នរោត្តម សីហនុ ប្រមុខរដ្ឋនៃកម្ពុជា ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា
- បានឃើញ ច្បាប់ស្តីពីពន្ធលើទំនិញនាំចេញ និង នាំចូល ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ៥៨ ក្រ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៨៨ ។
- បានឃើញលិខិតលេខ ១៨៧ សជណ.ពណ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៩៣ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការ កែសំរួល ប្រាក់ពន្ធគយ និង រដ្ឋាករ ។

### សំរេច

ប្រការ ១ ៖ យោងទៅតាមថ្លៃលក់ទំនិញនៅលើទីផ្សារទំនិញនាំចូលក្នុងចំនួនដែលជាប់អាករខ្ពស់ ហើយបាននាំចេញទៅវិញនោះ នឹងត្រូវបានសងប្រាក់ពន្ធវិញមានដូចខាងក្រោម ៖

- បារី ៥៥៥ , ម៉ាល់បូរ៉ូ , ខិនហ្វៀល , វីស្តុន សងប្រាក់ពន្ធវិញ ៦៤ % នៃប្រាក់ពន្ធគយ និង អាករ

| | | |
|---|---|---|
| - បារី ប្រភេទផ្សេងៗ | សងប្រាក់ពន្ធវិញ ៣៨ % | - ដ - |
| - ទូរទស្សន៍ | សងប្រាក់ពន្ធវិញ ៤៥ % | - ដ - |
| - វីដេអូ | សងប្រាក់ពន្ធវិញ ៣០ % | - ដ - |
| - ម៉ាញ៉េតូហ្វូន | សងប្រាក់ពន្ធវិញ ៤០ % | - ដ - |
| - ស្រាបៀរ | សងប្រាក់ពន្ធវិញ ៦៥ % | - ដ - |
| - ស្រា | សងប្រាក់ពន្ធវិញ ៥០ % | - ដ - |
| - រថយន្តធុនតូចថ្មី | សងប្រាក់វិញ ៥៥ % | - ដ - |
| - គ្រឿងយានយន្តថ្មី | សងប្រាក់ពន្ធវិញ ៥០ % | - ដ - |

ប្រការ ២ : ការអនុវត្តសងប្រាក់ពន្ធវិញ បានចំពោះតែទំនិញទាំងឡាយណាដែលនៅពេលនាំចូលបានបង់ពន្ធតាមតារាង ពន្ធគយថ្មីហើយនិងនាំចេញទៅវិញ ក្នុងរយៈពេលយ៉ាងយូរ ៣ ខែ ដោយគិតចាប់ពីថ្ងៃនាំចូល ។

ប្រការ ៣ : ប្រកាសនេះ មានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ១៩៩៣ ។

**រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ**

ហត្ថលេខា និង ត្រា

**សម រង្ស៊ី**

* * * *

# ឯកសារក្រសួងឧស្សាហកម្ម

## ប្រកាស

ភ្នំពេញ ថ្ងៃទី ៣ ខែ កញ្ញា ឆ្នាំ ១៩៩៣

**ប្រកាស លេខ : ១៩៤ ផក.ប្រក**

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម

- យោងព្រះរាជក្រឹត្យរបស់សម្តេចព្រះឧបយុវរាជ នរោត្តម សីហនុ ប្រមុខរដ្ឋនៃកម្ពុជា ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងសមាជិករដ្ឋមន្ត្រី

- យោងអនុក្រឹត្យលេខ ១២ អនក្រ ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ១៩៨១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រីស្តីពីការគ្រប់គ្រង ឧស្សាហកម្មតូច និង សិប្បកម្ម

- យោងលិខិតអនុញ្ញាតរបស់អភិបាលក្រុងភ្នំពេញលេខ ៧៦៣ ៣ អ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៨១

- បានឃើញពាក្យស្នើសុំបន្តផលិតកម្ម សិប្បកម្មអិដ្ឋ ក្បឿង របស់លោក អ៊ឹង ង៉ាក់សេង ចុះថ្ងៃទី ២៨ - ០៨ -

៩៣